កំណាព្យ

សុរិយាចាកមេឃ

បទពាក្យ ៧

សុរិយារះចាំងថែងភ្លឺត្រា[1] យាត្រាកាលមកឈរមុខភក្ត្រ
តែអ្នកមិនរវល់រាក់ទាក់ ជំពាក់មេត្តាដូចកាលរះ។
ដោយសារហេតុខ្ញុំជាមនុស្សក្រ កម្រមានមេត្តាពីរូបអ្នក
ដ្បិតកើតជាកូនអ្នកស្រែជាក់ ឥតបញ្ញាឃាត់បុណ្យអ្នកផង[2]។
មើលវិហានៅពេលស្រពិល ដល់ផ្លូវកំរិតបែកពុំផ្សង
សម្លឹងមេឃគ្មានមេត្តាក្រង តែក្រងចិត្តរង់ចាំស្រឡាញ់។
តើអ្នកភ្លេចខ្ញុំដែរឬនៅ ចាកទៅឆ្ងាយដោយគេពង្រាត់
បើអ្នកនៅស្រដោចព្រោះព្រាត់ ស្រណោក[3]ផងដល់ចិត្តរង់ចាំ។

---

[1] ត្រា : ដេរដាស។
[2] អ្នកផង : អ្នកដទៃ។
[3] ស្រណោក : ពាក្យសំរាប់និយាយផ្សំនឹងពាក្យ ស្រណោះស្រណោក : សេចក្តីសោកស្តាយ។